អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១

# <u>សេចក្តីប្រកាសព័ត៌មាន</u>

## សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៤

លោក Andrew Cayley ជាសហព្រះរាជអាជ្ញាអន្តរជាតិ សូមធ្វើសេចក្តីថ្លែងការណ៍នេះជាសាធារណៈ អនុលោមតាមមាត្រា ១២(២) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និង វិធាន ២១(គ) និងវិធាន ៥៤ នៃវិធានផ្ទៃក្នុង ដើម្បីធានាថា សាធារណជនទទួលបានព័ត៌មានទាន់ពេលវេលា អំពីកិច្ចដំណើរការនីតិវិធីកំពុងបន្តនៅ អ.វ.ត.ក នៅក្នុងសំណុំរឿង ០០៤ ដោយធ្វើការពិចារណាទៅលើផលប្រយោជន៍របស់ជនរងគ្រោះ និងសាក្សី សិទ្ធិរបស់ជនសង្ស័យ និងលក្ខខណ្ឌតម្រូវនៃការស៊ើបអង្កេត។

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានសម្រេចនៅក្នុងសំណុំរឿង ០០២ ថា វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុងកំណត់ឲ្យសហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចតាមផ្លូវច្បាប់ ក្នុងការជូនដំណឹងដល់ជនរងគ្រោះ "នៅក្នុងដំណើរការនីតិវិធី" អំពីឧក្រិដ្ឋកម្មដែលស្ថិតក្រោមការស៊ើបអង្កេត ហើយវាមិនគ្រប់គ្រាន់ទេដែលត្រឹមតែជូនដំណឹង "មុនពេលបញ្ចប់កិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ" នោះ។ ដូចដែលអង្គបុរេជំនុំជម្រះបានធ្វើការសន្និដ្ឋានគឺថា ដើម្បីឲ្យ "សិទ្ធិជាសារវន្តរបស់ជនរងគ្រោះ" "ត្រូវបានការពារឲ្យបានត្រឹមត្រូវនោះ" សហចៅក្រមស៊ើបអង្កេតត្រូវផ្តល់ "ការជូនដំណឹងឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ... ដល់ជនរងគ្រោះ នៅក្នុងដំណាក់កាលមុនជំនុំជម្រះ"។ គោលបំណងនៃលក្ខខណ្ឌនេះគឺដើម្បីធានាថា ជនរងគ្រោះមានឱកាសសមរម្យក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើឧក្រិដ្ឋកម្មជាក់លាក់ដែលស្ថិតក្រោមការស៊ើបអង្កេត នៅក្នុងរឿងក្តីជាក់លាក់ណាមួយ។

អនុលោមតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើមួយនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ដោយគោរពស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតចេញសេចក្តី

ថ្លែងការណ៍សាធារណៈមួយត្រឹមថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១ ដោយធ្វើការរៀបរាប់អំពីឧក្រិដ្ឋកម្ម និងបទល្មើសនានាដែលស្ថិតក្រោមការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤។